**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចព្រមព្រៀង ស្តីពីការព្យួរកិច្ចសន្យាការងារ</u>

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង០៨និង០០នាទីព្រឹក នៅក្នុងរោងចក្រផលិតស្បែកជើង ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី បានចុះកិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារជាមួយតំណាងសហជីពសហព័ន្ធសម្លេងយុវជនខ្មែរប្រចាំមូលដ្ឋាន ប្រចាំរោងចក្រផលិតស្បែកជើង ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី ដែលមានប្រការដូចខាងក្រោម៖

**ប្រការ១៖** ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន **៦០១**នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ចំនួន**៦១៥**នាក់ រយៈពេល **២ខែ គិតចាប់ពីថ្ងៃទី១ ខែឧសភា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០** ដោយមូលហេតុខ្វះការបញ្ជាទិញ។

**ប្រការ២៖** ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗ ចំនួន**៣០**ដុល្លារអាមេរិកក្នុង១ខែ ក្នុងនោះ៖

-ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ

-ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ

-ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ

ដោយព្រមព្រៀងបើករៀងរាល់ថ្ងៃទី១០។

**ប្រការ៣៖** ចំពោះប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលតាមរយៈភ្នាក់ងាររើង ដូចខាងក្រោម៖

-ចំនួន ១៥ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ

-ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ

-ចំនួន ៤០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ

ក្រោយព្យួរកិច្ចសន្យាការងាររយៈពេល ១០ថ្ងៃ។

ខេត្តតាកែវ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

តំណាងភាគីសហជីពមូលដ្ឋាន

ញ៉ៀម គន　　មោង ណារិន　　វ៉ាន់ លីតា

តំណាងភាគីក្រុមហ៊ុន

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ី.ស៊ី.អេហ្វ ស៊ូ មេនូហ្វេកធើរី C.C.F SHOES MANUFACTORY Co., Ltd. KINGDOM OF CAMBODIA